ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

# សុន្ទរកថា

*លោកជំទាវ **ជា សិរី** អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា*
*ថ្លែងក្នុងពិធីចុះហត្ថលេខាលើ កិច្ចព្រមព្រៀងរវាងធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិនៃ*
*ក្រសួងផែនការ ស្តីពីការធ្វើអង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៥*
*នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥*

**សូមគោរព !**

- ឯកឧត្តម **ទុយ ចំរើន** អនុរដ្ឋលេខាធិការ ក្រសួងផែនការ
- ឯកឧត្តម **ច័ន្ទ ទិត្យរ៉ាម៉ូ** អនុរដ្ឋលេខាធិការ នៃក្រសួងពាណិជ្ជកម្ម
- លោកជំទាវ **ហង់ លីណា** អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ
- លោក **Faisal Ahmed** តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា
- លោកស្រី **Elizabeth Alarilla** មន្ត្រីជាន់ខ្ពស់ផ្នែកស្ថិតិ នៃលេខាធិការដ្ឋានអាស៊ាន
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកនាងកញ្ញា ដែលអញ្ជើញមកពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងអ្នកតំណាងដែលអញ្ជើញមកពី ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងមន្ត្រីនៃធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ជាទីមេត្រី!

ជួសមុខឲ្យមន្ត្រីធនាគារជាតិនៃកម្ពុជា នាងខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក និងមានកិត្តិយសដ៏ឧត្តុង្គឧត្តម ដោយបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ទេសាភិបាល** ធនាគារជាតិនៃកម្ពុជាឲ្យចូលរួមពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការស្តីពីការធ្វើអង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៥ នាពេលនេះ ។ ថ្ងៃនេះជាទិវាដ៏ឱឡារិកដែលធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការរួមគ្នាចាប់ផ្តើមបង្កើតកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធិលើការធ្វើអង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៥ ដើម្បីចងក្រងស្ថិតិនេះ ឲ្យស្របតាមស្តង់ដាអន្តរជាតិ និងស្របតាមការអនុវត្តជាក់ស្តែង ។

ក្នុងរយៈកាល១០ឆ្នាំចុងក្រោយ សេដ្ឋកិច្ចកម្ពុជាបានរីកចម្រើនយ៉ាងឆាប់រហ័ស ដោយបានប្រែក្លាយពីសេដ្ឋកិច្ចដែលពឹងផ្អែកលើវិស័យចម្បងៗ ដូចជា កសិកម្ម រុក្ខាប្រមាញ់ នេសាទ និង



ប្រអប់សំបុត្រលេខ ២៥, ខ្សែតលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

សកម្មភាពផលិតកម្មដែលទទួលបានកម្រៃទាប ពិសេសឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ មកជាប្រទេសដែលដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យសេវាកម្ម ។ កម្ពុជានឹងបន្តជាប្រទេសទាក់ទាញបំផុតក្នុងវិស័យទេសចរណ៍ ដោយសារមរតកវប្បធម៌ និងធម្មជាតិ ពិសេសប្រាសាទអង្គរ ដែលនឹងនៅស្ថិតស្ថេរជាអមតៈ ។ ដូចបុព្វបុរសខ្មែរដែលបានកសាងទីក្រុងអង្គរ នាសម័យសាកលភាវូបនីយកម្មនេះ អ្នកកសាងជំនាន់ថ្មីភាគច្រើនជាវិនិយោគិនផ្ទាល់បរទេស ។ លើសពីនេះ អ្នកកសាងជំនាន់ថ្មីកំពុងនាំមុខក្នុងការកែប្រែមុខមាត់រាជធានីភ្នំពេញឲ្យក្លាយជាទីក្រុងលំដាប់ពិភពលោក តាមរយៈការកសាងទីក្រុងរណបជាច្រើន ។ មានមនុស្សជាច្រើនមិនដែលគិតដល់ថារាជធានីភ្នំពេញ អាចក្លាយជាទីក្រុងដែលមានទីផ្សារទំនើបកម្រិតពិភពលោក ឬមានអគារធំៗដែលជាទីតាំងរបស់គ្រឹះស្ថានហិរញ្ញវត្ថុកម្រិតពិភពលោកឡើយ ។ ទាំងនេះក៏ដោយសារតែមានការចូលរួមយ៉ាងខ្លាំងក្លារបស់អ្នក វិនិយោគផ្ទាល់បរទេស ផងដែរ ។

ទោះបីជាវិស័យកាត់ដេរសម្លៀកបំពាក់បានផ្តល់នូវតម្លៃបន្ថែមទាប ក្នុងខ្សែចង្វាក់ផលិតកម្មក្តីក៏ប៉ុន្តែវិស័យនេះបានជំរុញការអភិវឌ្ឍជំនាញបានមួយកម្រិតផងដែរ ។ នៅឆ្នាំ២០០៤ មនុស្សជាច្រើនបានព្យាករពីការដួលរលំនៃឧស្សាហកម្មកាត់ដេរ ដោយសារតែការបញ្ឈប់ការនាំចូលតាមប្រព័ន្ធអនុគ្រោះពន្ធទូទៅពីសំណាក់សហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក ប៉ុន្តែឧស្សាហកម្មកាត់ដេរនៅកម្ពុជានៅតែអាចរស់រានបាន និងរីកចម្រើនជាបន្តបន្ទាប់ ។ ឥទ្ធិពលនៃការអភិវឌ្ឍជំនាញបាននិងកំពុងជួយបំពេញតម្រូវការពលកម្ម និងជាម៉ាស៊ីនជំរុញឲ្យមានកំណើន ផងដែរ ។

តាមរយៈការធ្វើអង្កេតវិនិយោគផ្ទាល់បរទេសនេះនិងការអង្កេតផ្សេងទៀតនាពេលអនាគត ធនាគារជាតិនៃកម្ពុជា អាចមានលទ្ធភាពក្នុងការតាមដាននិងវាស់វែងពីទំហំដើមទុនបរទេសដែលកំពុងហូរចូលប្រទេសកម្ពុជា និងអាចពិនិត្យពីគុណប្រយោជន៍នៃវិនិយោគផ្ទាល់បរទេសមកលើសេដ្ឋកិច្ច ដូចជាការផ្ទេរជំនាញ និងបច្ចេកវិទ្យា ជាដើម ។ នេះគឺជារបទថ្មីមួយនៅកម្ពុជាដែលកំពុងតែកសាងកម្ពុជាឲ្យប្រែក្លាយជាប្រទេសមានមុខមាត់ថ្មីមួយក្នុងតំបន់ និងសកលលោក ។ ឧស្សាហកម្មផ្នែកសេវានៅកម្ពុជា នឹងនៅបន្តរីកចម្រើនទៅមុខទៀត ដែលអាចឆ្លុះបញ្ចាំងតាមរយៈការវិនិយោគក្នុងវិស័យហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធ ជាដើម ។

ការចាប់ផ្តើមការធ្វើអង្កេតវិនិយោគផ្ទាល់បរទេសឆ្នាំ២០១៥ សរបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លារបស់ធនាគារជាតិនៃកម្ពុជាក្នុងការអភិវឌ្ឍការចងក្រងស្ថិតិវិនិយោគអន្តរជាតិនៅកម្ពុជា ដែលសង្ឃឹមថានឹងអាចឆ្លើយតបនឹងចម្ងល់នានាពាក់ព័ន្ធនឹងគុណភាពនិងការចងក្រងស្ថិតិវិនិយោគផ្ទាល់បរទេសនេះ ។ កង្វះទិន្នន័យស្ថិតិវិនិយោគផ្ទាល់បរទេសគឺជាឧបសគ្គចម្បងមួយរបស់រាជរដ្ឋាភិបាល និងវិស័យឯកជន ព្រោះថាវិនិយោគិនត្រូវការស្ថិតិនេះ ដើម្បីពិនិត្យពីវិស័យសក្តានុពលក្នុងសេដ្ឋកិច្ច ទំហំទឹកប្រាក់ ដែលបានវិនិយោគ និងលទ្ធភាពរកចំណេញពីវិស័យទាំងនោះ ស្របពេលដែលរាជរដ្ឋាភិបាល អាចប្រើប្រាស់ព័ត៌មាននេះ ដើម្បីរៀបចំផែនការគៀងគរការវិនិយោគ ការបែងចែកធនធានបន្ថែមលើវិស័យអាទិភាព និងការកែលម្អនយោបាយលើកទឹកចិត្តចំពោះអ្នកវិនិយោគ ក្នុងគោលដៅរក្សាកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស ។ ព័ត៌មានស្ថិតិពីការអង្កេតនេះនឹងត្រូវបានប្រើប្រាស់ ជាធាតុចូលដ៏សំខាន់មួយក្នុងការកំណត់នូវគោលនយោបាយសេដ្ឋកិច្ច

ការរៀបចំផែនការអភិវឌ្ឍ យុទ្ធសាស្ត្រ និងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងបញ្ហាសាកលភាវូបនីយកម្ម ។ លើសពីនេះការធ្វើអង្កេតនេះ នឹងផ្តល់នូវឱកាសដ៏ល្អដល់មន្ត្រីជំនាញរបស់ធនាគារជាតិនៃកម្ពុជា និងមន្ត្រីជំនាញរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីកសាងសមត្ថភាពធនធានមនុស្ស និងផ្តល់នូវកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ និងផ្លាស់ប្តូរបទពិសោធន៍ជាក់ស្តែង និងចែករំលែកចំណេះដឹងទៅវិញទៅមក ។

ការបង្កើតនូវកិច្ចសហប្រតិបត្តិការលើការធ្វើអង្កេតនេះឡើង គឺដោយសារវិទ្យាស្ថានជាតិស្ថិតិមានសមត្ថភាព និងបទពិសោធន៍ក្នុងការធ្វើអង្កេតថ្នាក់ជាតិជាច្រើនកន្លងមក តួយ៉ាងថ្មីៗនេះវិទ្យាស្ថានជាតិស្ថិតិបានបញ្ចប់គម្រោងជំរឿនសហគ្រាសកម្ពុជា ឆ្នាំ២០១១ ដែលក្លាយជាធាតុចូលដ៏សំខាន់សម្រាប់ការធ្វើអនុវត្តការអង្កេតវិនិយោគផ្ទាល់បរទេស ប្រកបដោយជោគជ័យ ។

ជាថ្មីម្តងទៀត នាងខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរវាងមន្ត្រីនៃធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ក្នុងការយកចិត្តទុកដាក់ពិភាក្សាលើការងារបច្ចេកទេសរហូតឈានដល់ការសម្រេចបានកិច្ចព្រមព្រៀងនេះ ។ បន្ថែមលើនេះ នាងខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួងស្ថាប័នពាក់ព័ន្ធ រួមមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងស្ថាប័នផ្សេងទៀត ដែលតែងតែផ្តល់កិច្ចសហការ និងផ្លាស់ប្តូរទិន្នន័យស្ថិតិសំខាន់ៗ ជាមួយធនាគារជាតិនៃកម្ពុជាកន្លងមក ដើម្បីចូលរួមចងក្រង និងបោះពុម្ពផ្សាយស្ថិតិជញ្ជីងទូទាត់កម្ពុជា ប្រចាំត្រីមាស ប្រកបដោយនិរន្តភាព ។

នាងខ្ញុំស្នើសុំដោយទទូចដល់បណ្តាក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់មេត្តាបន្តពង្រឹងកិច្ចសហការដ៏ល្អជាប្រពៃណី ជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីជួយធ្វើឲ្យប្រសើរឡើងនូវគុណភាពស្ថិតិកម្ពុជា និងប្រព័ន្ធស្ថិតិជាតិទាំងមូល ។ នាងខ្ញុំក៏សូមស្នើសុំជំនួយ ការលើកទឹកចិត្ត និងការគាំទ្រដល់ការធ្វើអង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៥ នេះ ពីសំណាក់អង្គការអន្តរជាតិមួយចំនួន ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ។

ជាទីបញ្ចប់ នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម ជា ចាន់តូ** និងថ្នាក់ដឹកនាំ ធនាគារជាតិនៃកម្ពុជាទាំងអស់ និង ឯកឧត្តម ឆាយ ថន ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីនៃក្រសួងផែនការ ដែលតែងតែផ្តល់ការឧបត្ថម្ភគាំទ្រ និងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា មកលើវិស័យស្ថិតិកម្ពុជា ជាពិសេសគឺ ស្ថិតិវិស័យក្រៅប្រទេស និងស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ ។ ទន្ទឹមនេះ នាងខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកនាងកញ្ញាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីមកចូលរួម និងគាំទ្រក្នុងពេលនេះ ។ នាងខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកនាងកញ្ញាទាំងអស់ ឲ្យជួបប្រទះនូវពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបី ឃ្លៀងឃ្លាតឡើយ និងសូមឲ្យការធ្វើ អង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៥ ប្រព្រឹត្តទៅប្រកបដោយជោគជ័យ ។

**សូមអរគុណ!**